# Q&A

តើខ្ញុំគួរតែចាក់វ៉ាក់សាំង COVID-19 ដូសជំរុញថ្មីឬទេ?



Public Health
Seattle & King County

# ថ្នាំវ៉ាក់សាំង COVID-19 ដូសជំ រុញថ្មី

Q

## ហេតុអ្វីបានជាគេចេញថ្នាំវ៉ាក់ សាំង COVID-19 ដូសជំរុញថ្មី?

A

ក្រសួង CDC ណែនាំឱ្យចាក់ដូសជំរុញថ្មី (bivalent) អោយបាន 1 ដូស ប្រសិនបើវាមានរយៈពេលយ៉ាងហោច ណាស់ 2 ខែកន្លងមកហើយចាប់តាំងពីបានចាក់ដូសចុងក្រោយ សម្រាប់៖

- មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 5 ឆ្នាំឡើងទៅ
- កុមារអាយុ 6 ខែ - 4 ឆ្នាំដែលបានចាក់ថ្នាំវ៉ាក់សាំង Moderna សេរីដំបូង (មិនមានការណែនាំអោយចាក់ដូសជំរុញទេសម្រាប់កុមារអាយុ 6 ខែ - 4 ឆ្នាំដែលបានចាក់វ៉ាក់សាំង Pfizer) ។

# ថ្នាំវ៉ាក់សាំង COVID-19 ដូសជំរុញថ្មី

Q

## តើអ្នកណាគួរតែចាក់វ៉ាក់សាំង COVID-19 ដូសជំរុញថ្មី?

A

គ្រប់ៗគ្នាដែលលមានអាយុចាប់ ពី 5 ឆ្នាំឡើងទៅដែលបានចាក់ វ៉ាក់សាំង COVID-19 វគ្គដំបូងរួច មកហើយ ហើយនិង

យ៉ាងហោចណាស់ 2 ខែបាន កន្លងផុតទៅហើយ ចាប់តាំង ពីពួកគេបានចាក់វ៉ាក់សាំង ឬ ចាក់ដូសជំរុញចុងក្រោយ។

# ថ្នាំវ៉ាក់សាំង COVID-19 ដូសជំ រុញថ្មី

Q

## តើមានធាតុផ្សំអ្វីខ្លះនៅក្នុងថ្នាំវ៉ាក់សាំង COVID-19 ដូសជំរុញថ្មី?

A

ថ្នាំវ៉ាក់សាំងដូសជំរុញថ្មី Moderna និង Pfizer ប្រើធាតុ ផ្សំដូចគ្នា នឹងវ៉ាក់សាំង COVID-19 ដោយ មាន ការ ផ្លាស់ប្តូរប្រូតេអ៊ីន មួយ ប្រភេទដើម្បីប្រឆាំងនិងមេរោគបំលែងខ្លួន Omicron។

# ថ្នាំវ៉ាក់សាំង COVID-19 ដូសជំរុញថ្មី

**Q**

## តើមានផលប៉ះពាល់អ្វីខ្លះដែរ បណ្ដាលមកពីថ្នាំវ៉ាក់សាំង COVID-19 ដូសជំរុញថ្មី?

**A**

ដូចនិងថ្នាំវ៉ាក់សាំងផ្សេងទៀតដែរ វាអាចបណ្ដាលឱ្យឈឺដៃ ក្ដៅខ្លួន ឈឺក្បាល ឬអស់ កម្លាំង ក្រោយពី ចាក់រួច។ ផលប៉ះពាល់ទាំងនេះ ជាទូទៅ បាត់ ទៅវិញក្នុងរយៈ ពេលពីរបីថ្ងៃ។

# ថ្នាំវ៉ាក់សាំង COVID-19 ដូសជំរុញថ្មី

**Q**

## តើខ្ញុំគួរតែចាក់ថ្នាំវ៉ាក់សាំង COVID-19 ដូសជំរុញថ្មីប្រភេទ ណា?

**A**

អ្នកអាចជ្រើសរើសថ្នាំវ៉ាក់សាំង ដូសជំរុញថ្មីប្រភេទ Moderna ឬ Pfizer។ អ្នកមិនចាំបាច់ចាក់ ម៉ាកដូចគ្នានឹងថ្នាំ COVID-19 ដែលអ្នកបានចាក់កាលពីវគ្គ លើកមុនទេ។ (មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 5 ឆ្នាំឡើងទៅ)

# ថ្នាំវ៉ាក់សាំង COVID-19 ដូសជំរុញថ្មី

**Q**

## ខ្ញុំទើបតែកើតជំងឺកូវីដនៅ ពេលថ្មីៗនេះ។ តើខ្ញុំគួរតែ ចាក់វ៉ាក់ សាំង COVID-19 ដូសជំរុញថ្មី នៅពេលណា?

**A**

សូមរង់ចាំរហូតដល់អ្នកជាសះ ស្បើយរួចសិនហើយមិនមានរោគសញ្ញា។

សូមពិភាក្សាគ្នាជាមួយអ្នកផ្តល់សេវាថែទាំសុខភាពអំពីពេលវេលាដ៏ល្អបំផុតដើម្បីចាក់វ៉ាក់សាំងដូសជំរុញថ្មីនេះ។ អ្នកខ្លះអាច រង់ចាំ រហូតដល់ 3 ខែ ក្រោយពីការបាន ជាសះស្បើយវិញ។

# ថ្នាំវ៉ាក់សាំង COVID-19 ដូសជំរុញថ្មី

Q

## តើខ្ញុំអាចចាក់ថ្នាំវ៉ាក់សាំង COVD-19 ដូសជំរុញថ្មីនៅឯ ណា?

A

ថ្នាំវ៉ាក់សាំង COVID-19 ដូសជំរុញថ្មីអាចចាក់នៅមន្ទីរចាក់វ៉ាក់សាំងរបស់ក្រសួងសុខភាពសាធារណៈនៅ Auburn Outlet Mall (ស្វាគមន៍អ្នកដើរចូលដោយគ្មានណាត់ជួប បើកធ្វើការពីថ្ងៃសុក្រ-ច័ន្ទ)។

ឬអ្នកអាចសាកសួរអ្នកផ្តល់សេវាថែទាំសុខភាព មន្ទីរពិនិត្យសុខ ភាព ឬឱសថស្ថានក្នុងតំបន់។

# ថ្នាំវ៉ាក់សាំង COVID-19 ដូសជំរុញថ្មី

ថ្នាំវ៉ាក់សាំង COVID-19 ដូស ជំរុញ និងវ៉ាក់សាំង តែងតែ ឥតគិតថ្លៃជានិច្ច!

មិនចាំបាច់មានការធានារ៉ាប់រងសុខភាពឬមានភស្តុតាងបញ្ជាក់ថាជាសញ្ជាតិអាមេរិកទេ។

ចំពោះព័ត៌មានបន្ថែម សូមចូល ទៅកាន់៖

**kingcounty.gov/vaccine**

Public Health
Seattle & King County